

PreK 4 ME ការផ្សាភ្ជាប់គ្រួសារ

# មេរៀនទី 5 ៖ ស្រមោល និងការឆ្លុះត្រឡប់

***ទិដ្ឋភាពទូទៅនៃមេរៀនទី 5 ៖ ស្រមោល និងការឆ្លុះត្រឡប់***

*នៅក្នុងថ្នាក់រៀន យើងទាំងអស់គ្នា សប្បាយរីករាយជាមួយនឹងការស្វែងយល់ពីឥទ្ធិពលរបស់ពន្លឺមកលើមនុស្ស និងសត្វ ។ យើងនាំគ្នាដកពិសោធន៍ជាមួយនឹងពន្លឺ និងការបង្កើតជាស្រមោល រួចនាំគ្នាសង្កេតមើលថាតើវាមានការឆ្លុះត្រឡប់ដោយរបៀបណា ។ យើងបាននាំគ្នាសិក្សាអំពីទស្សនៈវិទ្យាសាស្ត្រទាំងនេះ ជាច្រើននៅខាងក្រៅ ហើយកសាងមូលដ្ឋានគ្រឹះសម្រាប់មេរៀនទី 6 ។ យើងបន្តរៀនសូត្រអំពីតួអក្សរ និងសូរសម្លេងរបស់វា និងបង្កើនវាក្យស័ព្ទរបស់យើង ក្នុងពេលយើងធ្វើកិច្ចការរួមគ្នានៅក្នុងថ្នាក់រៀន ដើម្បីបង្កើតការយល់ដឹង និងការទំនាក់ទំនងតាមរបៀបវិជ្ជមាន!*

## សៀវភៅសំខាន់នៃមេរៀនទី 5



*Raccoon on His Own*

ដោយ Jim Arnosky



*The Puddle Pail*

ដោយ Elisa Kleven



*Night Job*

ដោយ Karen Hesse



*Moonbear's Shadow*

ដោយ ៖ Frank Asch

រូបភាពដកស្រង់ចេញពី Amazon.com

**សៀវភៅផ្សេងទៀតដែលត្រូវអាន ៖**

*Play With Me* ដោយ ៖ Marie Hall Ets

*Kitten's First Full Moon*

ដោយ ៖ Kevin Henkes

*Guess Who's Shadow*

ដោយ ៖ Stephen R. Swinburne

*Clap Your Hands*

ដោយ ៖ Lorinda Bryan Cauley

## ចម្រៀង លេងជាមួយពាក្យ និងតួអក្សរ

ការច្រៀងជាពាក្យជូន និងការលេងពាក្យ គឺជាសកម្មភាពសប្បាយរីករាយ ហើយក៏ជាឧបករណ៍សំខាន់ ដែលយើងប្រើក្នុងថ្នាក់រៀន ដើម្បីបង្រៀនសិស្សពីទស្សនៈនៃចំនួន ។ នេះជាសកម្មភាពមួយ ដែលយើងបានរៀន ដែលអ្នកអាចយកទៅច្រៀងជាមួយកូនអ្នក ។ ឲ្យកូនអ្នកបង្ហាញអ្នកពីសកម្មភាពនេះ ដែលលេងនៅសាលា!

**កូនត្រីតូចចំនួនប្រាំ**

មានកូនត្រីប្រាំកំពុងហែលក្នុងបឹង
កូនត្រីទីមួយនិយាយថា "ទឹកបឹងនេះត្រជាក់ណាស់"
កូនត្រីទីពីរក៏និយាយថា "ទឹកបឹងនេះជ្រៅណាស់"
កូនត្រីទីបីនិយាយថា "ខ្ញុំចង់គេង"
កូនត្រីទីបួននិយាយថា "តោះយើងនាំគ្នាជ្រមុជដាំក្បាលចុះក្រោមឲ្យជ្រៅ "
កូនត្រីទីប្រាំនិយាយថា "ខ្ញុំឈ្លបឃើញកប៉ាល់ទឹកមួយគ្រឿង"
ទូកនេសាទចែវចូលមក
បោះសន្ទូចតម្រង់មក!
កូនត្រីទាំងប្រាំនាំគ្នាហែលគេចយ៉ាងរហ័ស!



រូបភាពដកស្រង់ពី Pixabay

សូមអានទំព័រម្ខាងទៀតអំពីសកម្មភាពនៅផ្ទះ

# ចូរបង្កើតការរៀនសូត្រនៅផ្ទះ ដោយប្រើសកម្មភាពបន្ថែមទាំងអស់នេះ!

## បទដ្ឋានសិក្សាគណិតវិទ្យា អារម្មណ៍សង្គម វិធីក្នុងការរៀនសូត្រ

### ការរាប់កាក់

ប្រមូលវត្ថុតូចៗឲ្យបាន 10 ដូចជាកាក់ ឬរបស់ផ្សេងទៀត នៅជុំវិញផ្ទះអ្នក ។ យករបស់នោះចំនួន 5 មកតម្រៀបគ្នា រួចសួរកូនអ្នកថារបស់ដែលអ្នកតម្រៀបគ្នានោះមានប៉ុន្មាន ។ ក្រោយពេលកូនអ្នករាប់របស់នោះរួចហើយ ត្រូវយកវាមកដាក់ចូលក្នុងរង្វង់ រួចឲ្យកូនអ្នករាប់របស់ក្នុងរង្វង់នោះថាមានប៉ុន្មាន ។

អ្នកអាចរករបស់បន្ថែមដាក់បញ្ចូលដើម្បីរាប់ចំនួនបន្ត ទៅតាមស្ថានភាពរបស់កូនអ្នក ។

## បទដ្ឋានសិល្បៈការច្នៃប្រឌិត វិទ្យាសាស្ត្រ វិធីសាស្ត្រការរៀនសូត្រ

### សិល្បៈស្រមោល

យករបស់មួយដាក់កណ្តាលវាលលើផ្ទៃរាបក្រោមពន្លឺព្រះអាទិត្យ (ឬក្រោមពន្លឺចង្កៀង ឬភ្លើងពិល) ដើម្បីឲ្យស្រមោលរបស់វាចាំងទៅលើក្រដាសមួយសន្លឹក ។ ឲ្យកូនអ្នកគូសតាមស្រមោលនៃវត្ថុនោះ ។ ពេលគូសរួចរាល់ហើយ ឲ្យកូនអ្នកផាត់ពណ៌តាមគំនូសស្រមោល ឬគូរឲ្យចេញជារូបរាងពិត

## បទដ្ឋានអក្សរសាស្ត្រ សិក្សាសង្គមវិទ្យាសាស្ត្រ និងការអភិវឌ្ឍន៍រាងកាយ

### សៀវភៅស្រមោល

រកសៀវភៅតូចសម្រាប់សរសេរចំនួនដប់ ឬយកក្រដាសកិបជាប់គ្នាធ្វើជាសៀវភៅ ។ ដើរមើលជុំវិញផ្ទះ ទីធ្លាជុំវិញផ្ទះ សួនច្បារ ឬទីណាដែលបង្កភាពងាយស្រួល ។ ឲ្យកូនអ្នកគូររូបតាមស្រមោល ដែលគាត់បានមើលឃើញក្នុងពេលដើរ ។ អ្នកអាចជួយកូនក្នុងការដាក់ឈ្មោះរូបភាព រួចសរសេរសៀវភៅស្រមោលរបស់អ្នកផ្ទាល់



រូបភាពដកស្រង់ពី Pixabay

## បណ្តាំចំពោះគ្រួសារ និងអ្នកមើលថែក្មេង ៖

កូនរបស់អ្នកកំពុងតែលូតលាស់ ដើម្បីចូលរៀនថ្នាក់មតេយ្យ ដែលវាមានន័យថា កូនអ្នកនឹងស្ថិតក្នុងភាពឯករាជ្យកាន់តែច្រើនជាងមុន ។ អ្នកអាចជ្រោមជ្រែងសកម្មភាពនេះ នៅផ្ទះ ៖

* ដាក់កិច្ចការងាយៗឲ្យកូនអ្នកធ្វើ អំពីអ្វីៗនៅក្នុងផ្ទះ ដូចជាយកខោអាវ ឬប្រដាប់លេងទៅទុកឲ្យផុត ឬជូតសំអាតតុក្រោយពេលបាយ ។
* ឲ្យកូណរៀនស្លៀកពាក់ខ្លួនឯង ជួយគាត់ខ្លះៗ បើចាំបាច់ ។
* ឲ្យកូនអ្នករៀបចំកាបូបទៅរៀនដោយខ្លួនឯង ។